Long Beach Water

# សេចក្តីជូនដំណឹង អំពីសវនាការសាធារណៈ

នាយកដ្ឋានទឹកនៃទីក្រុងឡុងប៊ិច នឹងបើកសវនាការសាធារណៈ នៅថ្ងៃទី 7 ខែមីនា ឆ្នាំ 2019 ដើម្បីធ្វើការពិចារណា លើការតវ៉ាសាធារណៈណាមួយ ចំពោះការកែប្រែ ដែលបានស្នើឡើង លើអត្រាថ្លៃសេវាទឹក និងអត្រាថ្លៃសេវាលូ របស់ក្រុង ដែលចូលជាធរមាន នៅថ្ងៃទី 1 ខែមេសា ឆ្នាំ 2019 ។ ម្ចាស់គណនីទឹក ឬគណនីលូ ទីក្រុងឡុងប៊ិចអាចធ្វើការតវ៉ា ចំពោះការកែប្រែ ដែលបានស្នើឡើង លើអត្រាថ្លៃសេវាទឹក និងអត្រាថ្លៃសេវាលូ របស់ក្រុង តាមរយៈបណ្តឹងតវ៉ា ជាលាយល័ក្ខណ៍អក្សរ ដែលត្រូវផ្ញើតាមប្រៃសណីយ៍ និងទទួលបាន នៅត្រឹមកាលបរិច្ឆេទបើកសវនាការសាធារណៈ ឬ យកទៅដាក់ដោយផ្ទាល់ នៅសវនាការសាធារណៈ ។

| **បណ្តឹងតវ៉ា ជាលាយល័ក្ខណ៍អក្សរ ត្រូវទទួលបាន នៅត្រឹមកាលបរិច្ឆេទសវនាការសាធារណៈ:** | **សវនាការសាធារណៈ: នៅថ្ងៃទី 7 ខែមីនា ឆ្នាំ 2019 វេលាម៉ោង 7:00 ល្ងាច** |
|---|---|
| គណៈកម្មាធិការទឹកនៃទីក្រុងឡុងប៊ិច<br>ជូនចំពោះ ៖ ជំនួយការប្រតិបត្តិ របស់ គណៈកម្មាធិការ<br>1800 វិថី East Wardlow<br>ឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា CA 90807 | រោងចក្រកែច្នៃសម្អាតទឹកក្រោមដីឡុងប៊ិច<br>បន្ទប់ប្រជុំ<br>2950 វុក្ខវិថី Redondo<br>ឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា CA 90807 |

| | | |
|---|---|---|
| ដើម្បីស្នើសុំការជូនដំណឹងនេះ ជាភាសាផ្សេង សូមទាក់ទងទូរសព្ទលេខ 562-570-2300 | *Para solicitar este aviso en otro idioma, llame al 562-570-2300* | *Para hilingin ang abisong ito sa alternatibong wika, pakitawagan ang 562-570-2300* |

## មានសំណើបង្កើនអត្រាថ្លៃសេវាទឹក ចំនួន 6 ភាគរយ ដោយចូលជាធរមាន នៅថ្ងៃទី 1 ខែមេសា ឆ្នាំ 2019

គណៈកម្មាធិការទឹកឡុងប៊ិច បានឯកភាព លើកំណើនអត្រាថ្លៃសេវាទឹក ដែលទូទាត់ដោយ អតិថិជនទាំងអស់ របស់នាយកដ្ឋានទឹកនៃទីក្រុងឡុងប៊ិច (LBWD) ដែលត្រូវមានសវនាការសាធារណៈ និង ការឯកភាព ពីក្រុមប្រឹក្សាក្រុង ។ កំណើនអត្រាថ្លៃទឹក នឹងបង្កើន ថ្លៃវិក្កយបត្ររួម របស់ទឹក និងលូ ជាប្រចាំខែ សម្រាប់គ្រួសារទោល ជម្មតា ចំនួន $2.74 (ដោយសន្មត ឯកតាគិតថ្លៃ ចំនួន 10 លើទាំងទឹក និងលូ) ។

**សំណើថ្លៃសេវាទឹក និងលូជាប្រចាំខែ**

| | បច្ចុប្បន្ន | កំណើន | សំណើ |
|---|---|---|---|
| **ទឹក** | $45.63 | $2.74 | $48.37 |
| **លូ** | $10.32 | $0.00 | $10.32 |
| **សរុប ប្រចាំខែ** | $55.95 | $2.74 | $58.69 |

**កំណត់សម្គាល់ ៖** តារាងបង្ហាញ ពីវិក្កយបត្រមធ្យម ប្រចាំខែ សម្រាប់សេវាទឹក និងលូ ប្រចាំខែ របស់គ្រួសារទោល ជម្មតា ដោយសន្មតត្រឹម ឯកតាគិតថ្លៃ ចំនួន 10 ។ មួយ «ឯកតាគិតថ្លៃ» ស្មើនឹង 748 ហ្គាឡុង ។

## វិនិយោគ លើប្រព័ន្ធទឹក របស់យើង បង្កើនលទ្ធភាព របស់យើង ក្នុងការទទួលបាន ប្រភពផ្គត់ផ្គង់ទឹក ដែលមានថ្លៃទាបបំផុត ។

ដើម្បីបន្តធានាឱ្យមាន ការផ្គត់ផ្គង់ទឹកស្អាត ដែលអាចទុកចិត្តបាន ជូនដល់លោកអ្នក និង គ្រួសារ ឬ ធុរកិច្ច របស់លោកអ្នក, ហេដ្ឋារចនាសម្ព័ន្ធ ដែលយើងទាំងអស់គ្នា ពឹងអាស្រ័យ ដើម្បីទទួលបានទឹកស្អាត ប្រកបដោយសុវត្ថិភាពនោះ កំពុងត្រូវបាន កែលំអ ជាលក្ខណៈប្រព័ន្ធ ។ វិនិយោគ លើប្រព័ន្ធទឹក របស់យើង អនុញ្ញាតឱ្យយើងបង្កើន លទ្ធភាព របស់យើង ក្នុងការបូមទឹកក្រោមដី ដែលមានគុណភាពខ្ពស់ ដោយមានថ្លៃទឹកស្អាត ក្នុងកម្រិតទាបបំផុត ដូចមានបង្ហាញ ក្នុងកម្រិត I នៃថ្លៃសេវាទឹក របស់យើង ។ កំណើនវិនិយោគទាំងនេះ រួមមាន ការអភិវឌ្ឍ និងការស្តារឡើងវិញ លើអណ្តូងទឹកក្រោមដី បច្ចុប្បន្ន និងថ្មីៗ ព្រមទាំង វិនិយោគ លើបច្ចេកវិទ្យា ដែលគាំទ្រ ដល់ប្រតិបត្តិការ នៃរោងចក្រកែច្នៃសម្អាតទឹកក្រោមដីឡុងប៊ិចរបស់យើង ។ ដោយកំណត់អាទិភាពវិនិយោគ របស់យើង លើប្រភពទឹកក្រោមដី, យើងអាចកាត់បន្ថយ ការពឹងអាស្រ័យ លើប្រភពផ្គត់ផ្គង់ទឹកនាំចូល ដែលមានថ្លៃខ្ពស់ជាងនេះ ។

វិនិយោគជោគជ័យរបស់យើង លើហេដ្ឋារចនាសម្ព័ន្ធ ដែលកាន់តែចាស់ទៅ សបញ្ជាក់ទៅដោយ ចំនួនបែកធ្លាយទឹក ជាចំបង ដែលយើងបានជួបប្រទះ ជារៀងរាល់ឆ្នាំ ។ ដោយប្រៀបធៀបទៅនឹង បទដ្ឋានឧស្សាហកម្ម នៃការបែកធ្លាយចំបង ចំនួន 100 ជាប្រចាំឆ្នាំ សម្រាប់សេវាទឹកភ្លើង ក្នុងទំហំ របស់យើង, នាយកដ្ឋានទឹកនៃទីក្រុងឡុងប៊ិច (LBWD) ជួបប្រទះ តែការបែកធ្លាយចំបង ចំនួន 30 ក្នុងមួយឆ្នាំ ប៉ុណ្ណោះ ។



## អត្រាថ្លៃសេវាទឹក និងលូ របស់ ឡុងប៊ិច ប្រៀបធៀបទៅនឹង ទីក្រុងធំៗ ផ្សេងទៀតនៅក្នុងរដ្ឋ ។




* រួមមាន ថ្លៃសេវាមណ្ឌលអនាម័យ ចំនួន $14.08 របស់តំបន់ឡូស អែនជីឡេស
** អត្រាថ្លៃសេវាទឹក នៅរដ្ឋហ្គោលខែន និង អត្រាថ្លៃសេវាលូ នៅឡុងប៊ិចរួមគ្នា

### អតិថិជន របស់យើង រីករាយនឹង អត្រាថ្លៃសេវាទឹក និងលូ លក្ខណៈពិសេស ដែលពួកគេទទួលបាន ។

យើងទទួលខុសត្រូវលើសុខភាព និង សុខមាលភាព ព្រមទាំង គុណភាពជីវិត របស់សហគមន៍ យ៉ាងម៉ត់ចត់ ។ យើងខិតខំ ក្នុងគ្រប់វិធី ដើម្បីផ្តល់សេវាអតិថិជន និង គុណតម្លៃល្អ លក្ខណៈពិសេស សម្រាប់អតិថិជនយើង រួមទាំង ប្រតិបត្តិដាក់កម្រិត ផ្នែកហិរញ្ញវត្ថុ និង ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយភាពច្បាស់លាស់ ។

អតិថិជនរបស់នាយកដ្ឋានទឹកនៃទីក្រុងឡុងប៊ិច (LBWD) ក៏រីករាយនឹងទទួលបានទឹកគុណភាពល្អវិសេស ជាប្រចាំ ដែលបំពេញបាន តាមបទដ្ឋានទឹកស្អាត ទាំងអស់ សម្រាប់ទឹកស្អាត និង មានសុវត្ថិភាព ។ របាយការណ៍គុណភាព ទឹក ប្រចាំឆ្នាំ មានដាក់នៅ លើគេហទំព័រនៅ **lbwater.org/annual-water-quality-report** ។

យើងក៏ផ្តល់កម្មវិធីគាំទ្រអតិថិជន និងគំនិតផ្តួចផ្តើម ជាច្រើន ប្រកបដោយនវានុវត្តន៍រួមទាំង កម្មវិធីសំណង ប្រាក់ និងមានគ្រឿងលើកទឹកចិត្ត សម្រាប់ទាំងការប្រើប្រាស់ទឹក នៅក្នុង និង នៅក្រៅអាគារផងដែរ ។

**សេចក្តីជូនដំណឹង ផ្លូវច្បាប់ អំពី សំណើ លេខ 218**

ពាក់ព័ន្ធនឹង សំណើកែប្រែអត្រាថ្លៃសេវាទឹក និង សវនាការសាធារណៈ

Long Beach Water


គណៈកម្មាធិការទឹកឡុងប៊ិច
1800 វិថី East Wardlow
ឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា CA 90807


មានចាត់ថ្នាក់ ជាស្រេច
បទដ្ឋាន
តែមប្រៃសណីយ៍ ស.រ.អ
បានទូទាត់
ឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា CA
លិខិតអនុញ្ញាត លេខ 1680